# សន្និបាតបូកសរុបលទ្ធផលការងារ
# ប្រចាំឆ្នាំ២០២៤ និង ទិសដៅអនុវត្តឆ្នាំ២០២៥
## ក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អាជ្ញាធរទន្លេសាប

## លទ្ធផលការងារគ្រប់គ្រង និងអភិរក្សធនធានទឹកប្រចាំ២០២៤ និង ទិសដៅអនុវត្តឆ្នាំ២០២៥

នាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក



# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

## ៤.១. សមិទ្ធផលកម្មវិធីថវិកាជាតិ

1. បានរៀបចំកម្រងព័ត៌មានអាងទន្លេបាន ២ អាងទន្លេ (អាងស្ទឹងបំណាក និងស្ទឹងពោធិសាត់)
2. បានផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា ក្នុង៤ព្រឹត្តិការណ៍ធំ
3. ចុះពិនិត្យដល់ទីតាំងលើសំណើសុំប្រើប្រាស់ទឹកបាន ៥ ទីតាំង
4. ចុះអន្តរាគមន៍ដល់ទីតាំងលើការទន្ទ្រានយកដីអាងតម្កលទឹក ចំណីផ្លូវទឹកបាន ១៨ កន្លែង
5. ចុះពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើសំណងការងារទឹក ៦ កន្លែង

## ៤.២. សមិទ្ធផលក្រោមការគាំទ្រពីគម្រោង WAT4CAM

1. ការកសាងសមត្ថភាព ការគាំទ្រដល់ការអនុវត្តដំណើរការ (IWRM)ក្នុងអាងស្ទឹងសែន អាងស្ទឹងសង្កែ និងអាងស្ទឹងទន្លេសាប
2. រៀបចំសេចក្តីព្រៀងការបង្កើតគណៈកម្មាធិការគ្រប់គ្រងអាងទន្លេស្ទឹងសង្កែ
3. រៀបចំកម្រងព័ត៌មានអាងស្ទឹងសង្កែ

## ៤.៣. សមិទ្ធផលក្រោមកិច្ចសហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ

1. រៀបចំកកម្រោងព័ត៌មានអាងទន្លេ
2. ផ្សព្វផ្សាយអនុក្រឹត្យស្តីពីគ្រប់គ្រងអាងទន្លេ និងតួនាទីភារកិច្ចរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ និងតួនាទីភារិច្ចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ

## ចំនួន (គិតជាដង)ការងារប្រជុំ សិក្ខាសាលា បណ្តុះបណ្តាល ក្នុង និងក្រៅប្រទេស



# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ (កម្រងរូបភាពនៃសមិទ្ធផល)

## ១. ១ កម្រងរូបភាពផ្សព្វផ្សាយលិខិតបទដ្ឋានទាក់ទងនឹងធនធានទឹក

















# ១. ១ កម្រងរូបភាពផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធនឹងធនធានទឹក

















# ១. ២ កម្រងរូបភាពចុះពិនិត្យទីតាំងស្នើសុំប្រើប្រាស់ទឹក







ចុះពិនិត្យទីតាំងប្រើប្រាស់ទឹកក្រោមដីរបស់ក្រុមហ៊ុន TOP SPORTS TEXTILE LTD ក្រុងបាវិត ខេត្តស្វាយរៀង (១៩ មករា ២០២៤)







ចុះពិនិត្យទីតាំងស្នើសុំការអនុញ្ញាតប្រើប្រាស់ទឹកក្រោមដីសម្រាប់ដំណើរការរោងចក្រផលិតសំភារៈកីឡា ដាប់ប៊ែលយូភី ស្ព័ត (ខេមបូឌា) ឯ.ក ក្នុងខេត្តស្វាយរៀង (២ កុម្ភៈ ២០២៤)





ចុះពិនិត្យទីតាំងស្នើសុំការអនុញ្ញាតប្រើប្រាស់ទឹកក្រោមដីនៅរោងចក្រផលិតស៊ីម៉ងត៍ របស់ក្រុមហ៊ុន ជីបម៉ុង អ៊ីនស៊ី ស៊ីមេនខបភើរេសិន (CMIC) ក្នុងខេត្តកំពត (១៧/៥/២០២៤)





ចុះពិនិត្យទីតាំងស្នើសុំការអនុញ្ញាតប្រើប្រាស់ទឹកទំនប់ ៧៨ សម្រាប់ផលិតផ្គត់ផ្គង់ទឹកស្អាត ដែលមានទីតាំងស្ថានីយនៅភូមិស្រម៉ធំ ឃុំដានរុន ស្រុកសូនិគម ខេត្តសៀមរាប (១២/៧/២០២៤)





ចុះពិនិត្យទីតាំងស្នើសុំប្រើប្រាស់ទឹកក្រោមដី របស់រោងចក្រផលិតកាបូប ជារួយហ្វេង (ខេមបូឌា) លេឌើរ ឯ.ក ស្ថិតនៅភូមិអង្គតាសិត ឃុំទួលពេជ្រ ស្រុលអង្គស្នួល ខេត្តកណ្តាល (២៨ វិច្ឆិកា ២០២៤

# ១.៣ ការចុះពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ការងារសាងសង់ទំនប់





ចុះពិនិត្យទីតាំងស្នើសុំវិនិយោគបង្កើតស្ថានីយវារីអគ្គិសនីខ្នាតតូច នៅស្ថានីយពាមឃ្លៃ ក្នុងភូមិ ពាមឃ្លៃ ឃុំទំព័រមាស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ (៧/១១/២០២៤)





ចុះពិនិត្យការការសាងសងសំណង់ទប់ទឹក ស្ថានីយ៍ផលិតទឹកស្អាត ខេត្តព្រះសីហនុ (ក្រុមហ៊ុន អានកូវជើរ ស៊ឹបផ្លាយ) នៅ ខេត្តព្រះសីហនុ (១៦/៧/២០២៤)

# ១.៤ កម្រងរូបភាពចុះកំណត់ព្រំប្រទល និងចំណីអាងទឹក





ចុះពិនិត្យទីតាំងផ្ទាល់ ដែលស្នើសុំបញ្ជាក់ពីផលប៉ះពាល់ដល់ចំណីស្ទឹង របស់ទីតាំងក្បាលដីចំនួន២ នៅអាងតម្កល់ទឹកទំនប់ ៧ មករា (២៣/៤/២០២៤)





ចុះពិនិត្យទីតាំងដីអាងទឹកតាកែវ ដែលសាខាគយនិងរដ្ឋាករខេត្តតាកែវស្នើសុំ សម្រាប់សាងសង់អាគាររដ្ឋបាល អាគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធសាខាគយនិងរដ្ឋាករខេត្តតាកែវ (៥/១១/២០២៤)

# ១.៥ កម្រងរូបភាពចុះពិនិត្យការទន្ទ្រានយកដីចំណីស្ទឹង និងទន្លេ







ចុះពិនិត្យទីតាំងផ្ទាល់ចំណីស្ទឹងព្រែកត្នោត នៅរាជធានីភ្នំពេញ (២៩/១០/២០២៤)







ចុះពិនិត្យទីតាំងផ្ទាល់នៅទីតាំងចាក់ដីចូលទន្លេ និងធ្វើប្រាំង នៅក្រុងអរិយ្សត្រ (២០/៩/២០២៤)

## ១.៦ កម្រងរូបភាពកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ







កិច្ចប្រជុំជាមួយ ឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លើការងារចុះបញ្ជីអាងស្តុកទឹក ដីប្រភាពទឹក (២/៤/២០២៤)







កិច្ចប្រជុំជាមួយក្រសួងរ៉ែ និងថាមពលលើការចែករំលែកព័ត៌មានការប្រើប្រាស់ទឹកដើម្បីផលិតអគ្គិសនី (១៤/៨/២០២៤)

# ២. បញ្ហាប្រឈម

- ទិន្នន័យ និងព័ត៌មានលើវិស័យធនធានទឹក និងធនធានដែលពាក់ព័ន្ធនឹងធនធានទឹក
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មាន
- ធនធានមនុស្ស/ជំនាញ ច្បាប់ ព័ត៌មានវិទ្យា និងការគ្រប់គ្រងធនធានទឹក
- ថវិកាក្នុងអនុវត្តទៅតាមតួនាទីភារកិច្ចរបស់នាយកដ្ឋាន ជាពិការកំណត់ព្រំប្រទលអាងទឹក និងការបោះបង្គោលព្រំ
- បទដ្ឋានគតិយុត្តក្នុងការការចុះបញ្ជីអ្នកប្រើប្រាស់ទឹក
- ឧបករណ៍បច្ចេកវិទ្យា និងមធ្យោបាយធ្វើដំណើរ
- ការសហការពីស្ថាប័នផ្សេងៗនៅមានកំរិត
- ការយល់ដឹងអំពីសារៈសំខាន់នៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក

**សំណូមពរ**

- បង្កើនថវិកា និងផ្តល់មធ្យោបាយធ្វើដំណើរ
- ពង្រឹងសមត្ថភាពមន្ត្រីមានស្រាប់
- ជ្រើសរើសមន្ត្រីដែលមានជំនាញពាក់ព័ន្ធ

# ៣. សេចក្តីសន្និដ្ឋាន

- ថ្វីត្បិតតែនាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក បានលើកសំណើរថវិកា ដើម្បីអនុវត្តសកម្មភាពកំណត់ព្រំអាងទឹក និងបោះបង្គោលព្រំដារាងរាល់ឆ្នាំ ប៉ុន្តែនាយកដ្ឋានមិនបានទទួលការគាំទ្រ តែនាយកដ្ឋានទទួលបានថវិកាមានកំណត់ក្នុងការអនុវត្តសកម្មភាពការងារនាយកដ្ឋាន
- ក្នុងរយៈពេល ០១ ឆ្នាំ កន្លងមកនេះ នាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក បានអនុវត្តនូវតួនាទីភារកិច្ចរបស់ខ្លួនតាមធនធានដែលមាន ដោយបានចុះប្រមូលទិន្នន័យដែលមានស្រាប់ដើម្បីរៀបចំលក្ខណសម្បត្តិរបស់អាងទន្លេ (Basin Profile) ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំក្នុង និងក្រៅក្រសួង ព្រមទាំងបានផ្សព្វផ្សាយគោលនយោបាយជាតិលើវិស័យធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក និងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ
- បានព្រាងលិខិតបទដ្ឋានដែលទាក់ទងទៅនឹងការស្នើសុំលិខិតអនុញ្ញាតិប្រើប្រាស់ទឹក ដូចដែលមានចែងនៅក្នុងមាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាការងារស្នូលរបស់នាយកដ្ឋាន ការចុះពិនិត្យលើសកម្មភាពរំលោភយកដីចំណីអាង ចុះពិនិត្យលើការស្នើប្រើប្រាស់ទឹកនៅតាមបណ្តាខេត្ត។

# ៤. ទិសដៅអនុវត្តឆ្នាំ២០២៥

I. **ថវិកាជាតិតាមកម្មវិធី**

1. ចប្រមូលព័ត៌មាន និងទិន្នន័យ ទាក់ទងនឹងធនធានទឹក ដើម្បីរៀបចំជាកម្រងព័ត៌មានអាងទន្លេ
2. ចុះបញ្ជីអ្នកប្រើប្រាស់ទឹកគ្រប់វិស័យ
3. ធ្វើអន្តរាគមន៍លើការទន្ទ្រានយកដីអាងតម្កលទឹក ដីចំណីអាងទឹក ចំណីទន្លេ ព្រែក ស្ទឹង អូរ និងប្រភពទឹក
4. បន្តផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក

II. **ការគាំទ្រពីគម្រោង** WAT4CAM

1. ការកសាងមន្ត្រីលើការគ្រប់គ្រងអាងទន្លេ និងការរៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងអាងទន្លេថ្នាក់ខេត្ត
2. ការគាំទ្រការកសាងសមត្ថភាពមន្ត្រី និងស្ថាប័ន

III. **ការសហការជាមួយជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ**

1. ការកសាងមន្ត្រីលើការគ្រប់គ្រងអាងទន្លេ និងការរៀបចំបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេថ្នាក់ខេត្ត
2. ការគាំទ្រការកសាងសមត្ថភាពមន្ត្រី និងស្ថាប័ន

សូមអរគុណ

THANK YOU

